**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីប្រកាសព័ត៌មានរួម

**ស្តីពី**

**ពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ**
**«គេហទំព័ររបស់មន្ទីរព័ត៌មានរាជធានី-ខេត្តទាំង២៥»**
**របស់ក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**

នាព្រឹកថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០២៦ នៅទីស្តីការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៃព្រះរាជាណាចក្រកម្ពុជា បានសហការគ្នារៀបចំពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ **«គេហទំព័ររបស់មន្ទីរព័ត៌មានរាជធានី-ខេត្តទាំង២៥»** ក្រោមអធិបតីភាពរបស់ **ឯកឧត្តម នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន និង **ឯកឧត្តម ជា វ៉ាន់ដេត** រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍**និងទូរគមនាគមន៍** ដោយមានការចូលរួមពីថ្នាក់ដឹកនាំនៃក្រសួងទាំងពីរ អ្នកនាំពាក្យក្រសួង-ស្ថាប័ន ប្រធានមន្ទីរព័ត៌មានរាជធានី-ខេត្ត តំណាងរដ្ឋបាលរាជធានី-ខេត្ត សមាគមអ្នកសារព័ត៌មាន សមាគមទូរទស្សន៍ និងសមាគមវិទ្យុ។

ការសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ «គេហទំព័ររបស់មន្ទីរព័ត៌មានរាជធានី-ខេត្តទាំង២៥» ឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តក្នុងការសហការគ្នាយ៉ាងជិតស្និទ្ធរវាងក្រសួងព័ត៌មាន និងក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ដើម្បីសម្រេចគោលដៅរួមតែមួយគឺ **ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋកាន់តែឆាប់រហ័ស កាន់តែទូលំទូលាយ កាន់តែមានប្រសិទ្ធភាព និងកាន់តែមានភាពជឿទុកចិត្តបាន។** កិច្ចការនេះជាផ្នែកមួយនៃការជំរុញបរិវត្តកម្មឌីជីថល និងការធ្វើទំនើបកម្មវិស័យព័ត៌មាននិងសោតទស្សន៍នៅព្រះរាជាណាចក្រកម្ពុជា ដើម្បីឈានទៅកសាងរដ្ឋាភិបាលឌីជីថលដ៏រឹងមាំ និងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។

ការដាក់ឱ្យដំណើរការគេហទំព័រទាំង២៥ មិនមែនគ្រាន់តែជាការបង្កើតវេទិកាថ្មីមួយសម្រាប់បង្ហោះព័ត៌មានប៉ុណ្ណោះទេ ប៉ុន្តែជាការបង្កើតមូលដ្ឋានសម្រាប់ **«ហេដ្ឋារចនាសម្ព័ន្ធព័ត៌មានឌីជីថល»** របស់មន្ទីរព័ត៌មានរាជធានី-ខេត្ត ដើម្បីឱ្យការគ្រប់គ្រង ការផលិត ការផ្សព្វផ្សាយ និងការចែករំលែកព័ត៌មានផ្លូវការ កាន់តែមានស្តង់ដារ ប្រសិទ្ធភាព និងទាន់ពេលវេលា។ គេហទំព័រទាំងនេះ នឹងឆ្លើយតបទៅនឹងតម្រូវការក្នុងការផ្លាស់ប្តូរពីការផ្សព្វផ្សាយតាមទម្រង់ប្រពៃណីតែមួយទៅកាន់ «ការផ្សព្វផ្សាយមាតិកាតាមថ្នាលពហុប្រព័ន្ធ» (Content Distribution Across Multi-Systems Platform) ដែលនឹងបង្កើតជាច្រកព័ត៌មានឌីជីថលសម្រាប់បង្ហាញសកម្មភាពការងារ សមិទ្ធផល និងព័ត៌មានសំខាន់ៗ នៅតាមរាជធានី-ខេត្ត ព្រមទាំងជួយភ្ជាប់ព័ត៌មានពីមូលដ្ឋានទៅកាន់សាធារណជនឱ្យកាន់តែងាយស្រួល។

ថ្លែងក្នុងពិធីសម្ពោធគេហទំព័រនេះ **ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មាន** បានគូសបញ្ជាក់ថា៖ *«ការសម្ពោធគេហទំព័រមន្ទីរព័ត៌មានរាជធានី-ខេត្តទាំង២៥ នៅថ្ងៃនេះ មិនមែនជាចំណុចបញ្ចប់ទេ វាគឺជាការចាប់ផ្តើមដំណើរថ្មីនៃការផ្សព្វផ្សាយព័ត៌មានផ្លូវការតាមប្រព័ន្ធឌីជីថល។ យើងចង់ឃើញគេហទំព័រទាំងនេះ ក្លាយជាប្រភពព័ត៌មានផ្លូវការដែលរស់រវើក ទាន់ពេលវេលា មានគុណភាព និងមានប្រយោជន៍ពិតប្រាកដសម្រាប់ប្រជាពលរដ្ឋ។ យើងត្រូវឱ្យប្រជាពលរដ្ឋដឹងថា នៅពេលពួកគាត់ចង់ស្វែងរកព័ត៌មានផ្លូវការ ពួកគាត់មានប្រភពដែលអាចពឹងផ្អែកបាន។ នេះជាការកសាងទំនុកចិត្តរបស់សាធារណជនចំពោះប្រព័ន្ធព័ត៌មានរបស់រដ្ឋ។»*

ក្នុងឱកាសនោះដែរ **ឯកឧត្តម ជា វ៉ាន់ដេត រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍** បានមានប្រសាសន៍ថា៖ *«ថ្នាលគ្រប់គ្រងមាតិកាព័ត៌មាន (Content Management Platform - CMP) ដែលយើងកំពុងប្រើប្រាស់ដើម្បីដាក់ដំណើរប្រព័ន្ធគេហទំព័ររបស់មន្ទីរព័ត៌មានរាជធានី-ខេត្តទាំង២៥ កំពុងក្លាយជាហេដ្ឋារចនាសម្ព័ន្ធឌីជីថល (Digital Public Infrastructure) ថ្មីមួយទៀត និងជាឃ្នាស់សម្រាប់ជំរុញការដាក់ដំណើរការប្រព័ន្ធគេហទំព័រនៃស្ថាប័នរាជរដ្ឋាភិបាលផ្សេងៗទៀតទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលធានាបាននូវអធិបតេយ្យភាពឌីជីថល សន្តិសុខប្រព័ន្ធ និងចីរភាព។»*។

គេហទំព័រមន្ទីរព័ត៌មានរាជធានី-ខេត្តទាំង ២៥ ត្រូវបានអភិវឌ្ឍនិងដាក់ដំណើរការលើ*ថ្នាលគ្រប់គ្រងមាតិកាព័ត៌មាន (CMP)* រួមមួយ ដែលអាចឱ្យមន្ទីរព័ត៌មាននីមួយៗគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពមាតិការបស់ខ្លួន។ ថ្នាល CMP មានមុខងារគាំទ្រដល់ការគ្រប់គ្រងគេហទំព័រច្រើននៅក្នុងបណ្តាញរួម ការតភ្ជាប់ទិន្នន័យជាមួយប្រព័ន្ធផ្សេងៗ ការកំណត់ និងគ្រប់គ្រងសិទ្ធិអ្នកប្រើប្រាស់ ការផ្ទៀងផ្ទាត់ពីរជំហាន ការកត់ត្រាប្រតិបត្តិការ ក៏ដូចជាមុខងារផ្សេងៗទៀត។ ការរៀបចំថ្នាល CMP នេះ មានគោលដៅធ្វើឱ្យការគ្រប់គ្រងព័ត៌មានផ្លូវការនៅរាជធានី-ខេត្ត មានស្តង់ដាររួមតែមួយ ព្រមទាំងកាត់បន្ថយការងារស្ទួនគ្នា ពង្រឹងសុវត្ថិភាពឌីជីថល និងបង្កើនប្រសិទ្ធភាពនៃការចែករំលែកព័ត៌មាន។

ដើម្បីធានានូវនិរន្តរភាពនៃគេហទំព័រនេះ ក្រសួងព័ត៌មានបានណែនាំឱ្យមន្ទីរនីមួយៗកំណត់មន្ត្រីទទួលបន្ទុកឱ្យបានច្បាស់លាស់ ទាំងការគ្រប់គ្រងប្រព័ន្ធ ការសរសេរ ការកែសម្រួល និងការបញ្ចូលមាតិកា។ មុននឹងផ្សព្វផ្សាយព័ត៌មាន ត្រូវឆ្លងកាត់ការត្រួតពិនិត្យប្រភព ភាពត្រឹមត្រូវ អក្ខរាវិរុទ្ធ ចំណងជើង រូបភាព និងព័ត៌មានពាក់ព័ន្ធ ដោយគោរពតាមស្តង់ដារវិជ្ជាជីវៈ។ ជាមួយគ្នានេះ មន្ទីរត្រូវយកចិត្តទុកដាក់លើសុវត្ថិភាពប្រព័ន្ធ ការគ្រប់គ្រងគណនី និងការកំណត់សិទ្ធិអ្នកប្រើប្រាស់ ដើម្បីការពារប្រភពព័ត៌មានផ្លូវការពីហានិភ័យសន្តិសុខឌីជីថល។ ទន្ទឹមនេះដែរ ក្រសួងទាំងពីរ នឹងបន្តសហការគ្នាធ្វើបច្ចុប្បន្នភាពគេហទំព័រនេះជាប្រចាំទាំងបច្ចេកទេស ទាំងមាតិកា ដោយមិនទុកឱ្យគេហទំព័រនេះក្លាយជាវេទិកាដែលមានតែព័ត៌មានចាស់ៗឡើយ។

ក្នុងពិធីសម្ពោធគេហទំព័រមន្ទីរព័ត៌មានរាជធានី-ខេត្តទាំង២៥នេះ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក៏បានផ្តល់កុំព្យូទ័រចំនួន៥០គ្រឿងដល់មន្ទីរព័ត៌មានទាំង២៥រាជធានី-ខេត្ត ដើម្បីជួយសម្រួលដល់ការបំពេញកង្វះខាតផ្នែកឧបករណ៍ បង្កើនសមត្ថភាពមន្ត្រី លើកកម្ពស់ប្រសិទ្ធភាពការងារ និងជួយធានាថា ការបំប្លែងការងារព័ត៌មានទៅជាប្រព័ន្ធឌីជីថល អាចប្រព្រឹត្តទៅបានប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

គេហទំព័រទាំងនេះ នឹងប្រើប្រាស់ «អត្តសញ្ញាណឌីជីថលរួម» (Unified Digital Identity) ក្រោមអនុដែនជាតិ«.info.gov.kh»។ សាធារណជនទូទៅអាចចូលប្រើប្រាស់គេហទំព័ររបស់មន្ទីរព័ត៌មានរាជធានី-ខេត្ត ទាំង២៥ តាមរយៈតំណភ្ជាប់ «https://www. ឈ្មោះខេត្តនីមួយៗ .info.gov.kh»។

ថ្ងៃអង្គារ ១១កើត ខែភទ្របទ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០២៦

**ក្រសួងព័ត៌មាន** **ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**